**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ**

**លេខ** : ១៥ ប្រ.ក.


នាយកដ្ឋានមុខងារ និងធនធាន
ចូល លេខ: ៤៤១
ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ២០១៩
បញ្ជូន:


# ប្រកាស
## ស្តីពី
## ការគ្រប់គ្រងការប្រគំតន្ត្រីតាមទីសាធារណៈ

## រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី០៥ ខែមីនា ឆ្នាំ២០០៣ ប្រកាសឲ្យប្រើច្បាប់ស្តីពីសិទ្ធិអ្នកនិពន្ធនិងសិទ្ធិប្រហាក់ប្រហែល
- បានឃើញអនុក្រឹត្យលេខ២៤ អនក្រ.បក. ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក. ចុះថ្ងៃទី១០ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដំណើរការទូទៅនៃការផ្ទេរមុខងារនិងធនធានឲ្យទៅដល់រដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ៦៨ អនក្រ.បក. ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ១៨ អនក្រ.បក. ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅរដ្ឋបាលថ្នាក់ក្រោមជាតិ
- បានឃើញប្រកាសរួមលេខ៦៥៧ សហវ.ប្រក. ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
- បានឃើញប្រកាសរួមលេខ១៤៣៤២ ប្រ.ក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ រវាងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការផ្តល់សេវារដ្ឋបាលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ
- យោងតាមការចាំបាច់របស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ



ទូរសព្ទ / ទូរសារៈ 023 218 148 , E-mail : info@mcfa.gov.kh, www.mcfa.gov.kh, ប្រអប់សំបុត្រ 72
មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលបំណងលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិនិងអន្តរជាតិនៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**ប្រការ២.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីនីតិវិធីនៃការដាក់ពាក្យស្នើសុំ សមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាត ការផ្អាកនិងបញ្ឈប់ជាផ្លូវការ និងការកំណត់សេវារដ្ឋបាលក្នុងការធានានូវសុវត្ថិភាព គុណភាព និងសក្តិសិទ្ធភាព ដើម្បីជៀសវាងការធ្វើឲ្យប៉ះពាល់ដល់ប្រពៃណីវប្បធម៌ជាតិនៅពេលប្រគំតន្ត្រី។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្តចំពោះការប្រគំតន្ត្រីតាមទីសាធារណៈ លើកលែងការប្រគំតន្ត្រីក្នុងកម្មវិធីរៀបអាពាហ៍ពិពាហ៍ ឬ កម្មវិធីផ្សេងៗជាលក្ខណៈឯកជន។

**ប្រការ៤.-**

វាក្យសព្ទដែលប្រើក្នុងប្រកាសនេះ ត្រូវបានកំណត់លក្ខខណ្ឌនិងនិយមន័យដូចខាងក្រោម៖

១- ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលដាក់ពាក្យស្នើសុំ ត្រូវមានលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- ការសម្តែង ឬ ការប្រគំឧបករណ៍តូរ្យតន្ត្រី មានការចូលរួមពីតន្ត្រីករ ឬ សិល្បករនិងសិល្បការិនីជនជាតិខ្មែរ
- ករណីមានការចូលរួមពីតន្ត្រីករឬសិល្បករនិងសិល្បការិនីសញ្ជាតិបរទេស លុះត្រាតែតន្ត្រីករ ឬ សិល្បករនិងសិល្បការិនីនោះមានលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

២- ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈអន្តរជាតិ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលដាក់ពាក្យស្នើសុំ មាន ឬ ពុំមានលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា
- ការសម្តែង ឬ ការប្រគំឧបករណ៍តូរ្យតន្ត្រី មាន ឬ មិនមានការចូលរួមពីតន្ត្រីករ ឬ សិល្បករនិងសិល្បការិនីជនជាតិខ្មែរ
- មានការចូលរួមពីតន្ត្រីករ ឬ សិល្បករនិងសិល្បការិនីសញ្ជាតិបរទេសដែលពុំមានលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។

៣- នីតិបុគ្គល សំដៅដល់ក្រុមមនុស្ស ឬ មូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាម្ចាស់នៃសិទ្ធិនិងកាតព្វកិច្ច

៤- រូបវន្តបុគ្គល សំដៅដល់មនុស្សពិតដែលផ្ទុយនឹងនីតិបុគ្គល

៥- សក្តិសិទ្ធភាព សំដៅដល់ភាពដែលអាចឲ្យសម្រេចប្រយោជន៍បាន។

## ជំពូកទី២
## នីតិវិធីនៃការដាក់ពាក្យស្នើសុំ

**ប្រការ៥**.-

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលមានបំណងដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតការប្រគំតន្ត្រីតាមទីសាធារណៈ ត្រូវបំពេញបែបបទស្នើសុំមកអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឬ ការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ តាមគំរូពាក្យស្នើសុំដូចភ្ជាប់ក្នុងឧបសម្ព័ន្ធទី១និងឧបសម្ព័ន្ធទី២នៃប្រកាសនេះ។

**ប្រការ៦**.-

រូបវន្តបុគ្គល ឬ នីតិបុគ្គលដែលបានដាក់ពាក្យស្នើសុំលិខិតអនុញ្ញាតការប្រគំតន្ត្រីតាមទីសាធារណៈ ត្រូវសហការជាមួយអាជ្ញាធរមូលដ្ឋាននិងអង្គភាពពាក់ព័ន្ធ ដើម្បីធានាបាននូវសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថានល្អ។

**ប្រការ៧**.-

បុគ្គលិកជួរក្រោយនៃអង្គភាព ឬ ការិយាល័យច្រកចេញចូលតែមួយ ត្រូវស្នើសុំកិច្ចសហការជាមួយអាជ្ញាធរមានសមត្ថកិច្ច ចុះពិនិត្យដល់ទីកន្លែងនៃការប្រគំតន្ត្រីតាមទីសាធារណៈមុននឹងផ្តល់យោបល់បច្ចេកទេសជូនប្រធានអង្គភាពច្រកចេញចូលតែមួយរាជធានី ខេត្ត ឬ ប្រធានការិយាល័យច្រកចេញចូលតែមួយក្រុង ស្រុក ខណ្ឌ ដើម្បីដាក់ជូនអភិបាលរាជធានី ខេត្ត ឬ អភិបាលក្រុង ស្រុក ខណ្ឌ ដើម្បីពិនិត្យសម្រេច។

## ជំពូកទី៣
## សមត្ថកិច្ចក្នុងការចេញលិខិតអនុញ្ញាត

**ប្រការ៨**.-

រដ្ឋបាលក្រុង ស្រុក ខណ្ឌ មានសិទ្ធិចេញលិខិតអនុញ្ញាតការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិតាមរយៈការិយាល័យច្រកចេញចូលតែមួយ។

ក្នុងករណីក្រុង ស្រុក ខណ្ឌពុំមានការិយាល័យច្រកចេញចូលតែមួយ ការចេញលិខិតអនុញ្ញាតត្រូវអនុវត្តតាមប្រការ១២នៃប្រកាសអន្តរក្រសួងលេខ១៣៤២៤ ប្រ.ក. ចុះថ្ងៃទី២៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវារដ្ឋបាលថ្នាក់ក្រោមជាតិរបស់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៩**.-

រដ្ឋបាលរាជធានី ខេត្ត មានសិទ្ធិចេញលិខិតអនុញ្ញាតការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈអន្តរជាតិតាមរយៈអង្គភាពច្រកចេញចូលតែមួយ។

## ជំពូកទី៤
## ការផ្អាកនិងបញ្ឈប់ជាផ្លូវការ

**ប្រការ១០**.-

ត្រូវបានហាមឃាត់ដាច់ខាតនូវរាល់ការប្រគំតន្ត្រី ឬ ការសម្តែងណាដែលប៉ះពាល់អង្គព្រះមហាក្សត្រ រើសអើងជាតិសាសន៍ ភេទ ព័ណ៌សម្បុរ ភាសា ជំនឿ សាសនា ឬ និន្នាការនយោបាយដែលប្រឆាំងទៅនឹងបូរណភាពទឹកដី ឯករាជ្យជាតិ សន្តិភាព អធិបតេយ្យជាតិ សន្តិសុខជាតិ និងរាល់សកម្មភាពណាដែលជះឥទ្ធិពលអវិជ្ជមានដល់វប្បធម៌និងប្រពៃណីដ៏ល្អរបស់ជាតិ។

**ប្រការ១១**.-

ករណីមានភាពមិនប្រក្រតីកើតឡើងអំឡុងពេលប្រគំតន្ត្រីជាលក្ខណៈជាតិ អាជ្ញាធរមានសមត្ថកិច្ចមាន

សិទ្ធិផ្អាកជាបណ្តោះអាសន្ន។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវស្នើសុំប្រធានការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ ដើម្បីចេញលិខិតបញ្ឈប់ជាផ្លូវការពីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ។

**ប្រការ១២.-**

ករណីមានភាពមិនប្រក្រតីកើតឡើងអំឡុងពេលប្រគំតន្ត្រីជាលក្ខណៈអន្តរជាតិ អាជ្ញាធរមានសមត្ថកិច្ចមានសិទ្ធិផ្អាកជាបណ្តោះអាសន្ន។

អាជ្ញាធរមានសមត្ថកិច្ច ត្រូវស្នើសុំពីប្រធានអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ដើម្បីចេញលិខិតបញ្ឈប់ជាផ្លូវការពីអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត។

## ជំពូកទី៥
## ការកំណត់សេវារដ្ឋបាល

**ប្រការ១៣.-**

កម្រៃសេវា រយៈពេលនៃការផ្តល់សេវា និងសុពលភាពលិខិតអនុញ្ញាតការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិនិងអន្តរជាតិ ត្រូវអនុវត្តតាមប្រកាសរួមលេខ៦៥៧សហវ.ប្រក ចុះថ្ងៃទី០៦ ខែមិថុនា ឆ្នាំ២០១៦ រវាងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ លើកលែងតែមានការកំណត់ផ្សេងពីនេះ។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**ប្រការ១៤.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ១៥.-**

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានបេតិកភណ្ឌ អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេសវប្បធម៌ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរអប្សរា អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិព្រះវិហារ អគ្គនាយកនៃអគ្គនាយកដ្ឋានអាជ្ញាធរជាតិសំបូរព្រៃគុក សាកលវិទ្យាធិការនៃសាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ អធិការនៃអធិការដ្ឋាន ប្រធាននាយកដ្ឋានពាក់ព័ន្ធ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ប្រធានមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត និងបុគ្គលិកច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃសុក្រ ៥រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ភឿង-សកុណា**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- គ្រប់ក្រសួងស្ថាប័ន
- សាលារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- ដូចប្រការ១៥ "ដើម្បីអនុវត្ត"
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

(ឧបសម្ព័ន្ធទី១)

# ពាក្យស្នើសុំ
# ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ
# ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិ

ខ្ញុំបាទ-នាងខ្ញុំ ឈ្មោះ............................... អក្សរឡាតាំង ................................................
ភេទ..........ថ្ងៃខែឆ្នាំកំណើត...................... សញ្ជាតិ............... អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ..........
ផ្លូវ...........ភូមិ..................... ឃុំ/សង្កាត់...............................ក្រុង/ស្រុក/ខណ្ឌ..........................
រាជធានី/ខេត្ត...................... អត្តសញ្ញាណបណ្ណ / លិខិតឆ្លងដែនលេខ ..............................................
លេខទូរសព្ទទំនាក់ទំនង ........................................................................................................
ជាម្ចាស់/តំណាង.............................................................................................................។

**សូមគោរពជូន**
**លោក លោកស្រីអភិបាលនៃគណៈអភិបាលក្រុង ស្រុក ខណ្ឌ**

.................................................................................

**កម្មវត្ថុ** ៖ សំណើសុំប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិ។

សេចក្តីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **លោក លោកស្រីអភិបាលក្រុង ស្រុក ខណ្ឌ** មេត្តាជ្រាបថា៖ ក្រុមតន្ត្រី ................................................ របស់ខ្ញុំបាទ-នាងខ្ញុំមានបំណងប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិចាប់ពីថ្ងៃទី ..............ខែ.................. ដល់ថ្ងៃទី................ខែ.....................ឆ្នាំ.................. នៅ ........................................................ ................................................................................................................................ ។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **លោក លោកស្រីអភិបាល** មេត្តាពិនិត្យនិងសម្រេច។

*សូមផ្ញើភ្ជាប់មកជាមួយ៖*

១- អត្តសញ្ញាណបណ្ណរបស់អ្នកដាក់ពាក្យស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) ១ច្បាប់
២- លិខិតឆ្លងដែន និង លិខិតបញ្ជាក់លំនៅអចិន្ត្រៃយ៍របស់អ្នកដាក់ពាក្យស្នើសុំសញ្ជាតិបរទេស (ថតចម្លងដោយនីត្យានុកូលកម្ម) ១ច្បាប់
៣- កិច្ចសន្យា ១ច្បាប់
៤- បញ្ជីរាយនាមតន្ត្រីករ សិល្បករ និងសិល្បការិនី ១ច្បាប់
៥- លិខិតបញ្ជាក់លំនៅអចិន្ត្រៃយ៍របស់តន្ត្រីករ សិល្បករ និងសិល្បការិនីសញ្ជាតិបរទេស ១ច្បាប់

សូម **លោក លោកស្រីអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ........................ ខែ............. ឆ្នាំ........................ព.ស. ...........
ថ្ងៃទី.............ខែ................... ឆ្នាំ.............
ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
## ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ……………………………………ជាអក្សរឡាតាំង …………………………………………… ភេទ…………ថ្ងៃខែឆ្នាំកំណើត……………………… សញ្ជាតិ……………… អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ………… ផ្លូវ…… ភូមិ…………………… ឃុំ/សង្កាត់………………………………ក្រុង/ស្រុក/ខណ្ឌ ……………………រាជធានី/ខេត្ត …………………… តួនាទី (ម្ចាស់ ឬ អ្នកគ្រប់គ្រង)……………………………………… ប្រកបអាជីវកម្មឈ្មោះ (ខ្មែរនិងឡាតាំង) ………………………………………………………………………ទូរសព្ទ……………………………… ទូរសារ ……… ……… …………………អ៊ីម៉ែល ឬ វេបសាយ……………………………………………។

### សូមធ្វើកិច្ចសន្យាដូចខាងក្រោម៖

១- ជានាគោរពគោលការណ៍និងទម្រង់សិល្បៈរបស់ជាតិ មិនកែច្នៃខុសពីលំនាំដើម

២- ជានារាល់ការប្រគំតន្ត្រី ឬ សម្តែង ត្រូវគោរពតាមគោលការណ៍ណែនាំរបស់រដ្ឋបាលក្រុង ស្រុក ខណ្ឌ និងមន្ទីរវប្បធម៌និងវិចិត្រសិល្បៈរាជធានី ខេត្ត

៣- ជានាមិនធ្វើឲ្យប៉ះពាល់ដល់ទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ

៤- ជានារាល់ការប្រគំតន្ត្រី ឬ ការសម្តែងមិនឲ្យមានការប៉ះពាល់អង្គព្រះមហាក្សត្រ ការរើសអើងជាតិសាសន៍ ភេទ ព័ណ៌សម្បុរ ជំនឿ សាសនា ឬ និន្នាការនយោបាយដែលប្រឆាំងទៅនឹងបូរណភាពទឹកដី ឯករាជ្យជាតិ អធិបតេយ្យជាតិ ឬ សន្តិសុខជាតិ

៥- ជានាមិនឲ្យហួសម៉ោងកំណត់

៦- ជានាសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់

៧- ទទួលខុសត្រូវលើសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងបរិស្ថានល្អ

៨- សាមីខ្លួនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់រាល់ការសម្តែងដែលរំលោភបំពានផ្នែកកម្មសិទ្ធិបញ្ញា។

អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិផ្អាកជាបណ្តោះអាសន្ន ឬ បញ្ឈប់ជាផ្លូវការរាល់ការប្រគំតន្ត្រី ឬ ការសម្តែងណាដែលពិនិត្យឃើញថាមិនបានគោរពតាមកិច្ចសន្យាខាងលើ។

ករណីមិនអនុវត្តកិច្ចសន្យានេះ ខ្ញុំបាទ-នាងខ្ញុំសូមទទួលទោសតាមច្បាប់របស់រដ្ឋដែលបានកំណត់ជាធរមាន។

ថ្ងៃ………………………… ខែ…………… ឆ្នាំ…………………………ព.ស. …………

ថ្ងៃទី…………ខែ………………… ឆ្នាំ……………

**ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# បញ្ជីរាយនាម
# មន្ត្រីករ សិល្បករ និងសិល្បការិនីនៃការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិ

១. បញ្ជីរាយនាមតន្ត្រីករ សិល្បករ និងសិល្បការិនីជនជាតិខ្មែរ

| ល.រ. | គោត្តនាមនិងនាម | ភេទ | មុខងារ | អាសយដ្ឋានបច្ចុប្បន្ន | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |

២. បញ្ជីរាយនាមតន្ត្រីករ សិល្បករ និងសិល្បការិនីសញ្ជាតិបរទេសដែលមានលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា

| ល.រ. | គោត្តនាមនិងនាម | ភេទ | មុខងារ | អាសយដ្ឋានបច្ចុប្បន្ន | លេខលិខិតឆ្លងដែន | សញ្ជាតិ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |

ចំនួនសរុប.....................នាក់ ស្រី.........នាក់។

ថ្ងៃ............................ ខែ.............. ឆ្នាំ............................ព.ស. ............

ថ្ងៃទី.............ខែ..................... ឆ្នាំ..............

ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ……………………………….
**ការិយាល័យច្រកចេញចូលតែមួយ**
**លេខ** ………………………..

**លិខិតអនុញ្ញាត**
**ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈជាតិ**

**យោង ៖** – ប្រកាសលេខ៩២៨ ប្រ.ក ចុះថ្ងៃទី១២ ខែមីនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃការិយាល័យច្រកចេញចូលតែមួយនៅក្រុង ស្រុក ខណ្ឌគោលដៅ របស់ក្រសួងមហាផ្ទៃ
– ប្រកាសរួមលេខ២៦៥៧ សហវ.ប្រក រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
– ប្រកាសលេខ១៥ ប្រ.ក. ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្តីពីកាគ្រប់គ្រងការប្រគំតន្ត្រីតាមទីសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

អនុញ្ញាតឲ្យឈ្មោះ…………………………………….. ភេទ……….. ថ្ងៃខែឆ្នាំកំណើត……………………
……………………. សញ្ជាតិ……………………អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ………………. ផ្លូវ…………..
ភូមិ…………………. ឃុំ/សង្កាត់ ………………………….. ក្រុង/ស្រុក/ខណ្ឌ ………………………….
រាជធានី/ខេត្ត……………………….. អត្តសញ្ញាណបណ្ណ/លិខិតឆ្លងដែនលេខ ……………………………
ប្រគំតន្ត្រី នៅភូមិ……………. ឃុំ/សង្កាត់………………………… ស្រុក/ខណ្ឌ ……………………….
រាជធានី/ខេត្ត……………………….. ។
លិខិតអនុញ្ញាតនេះមានសុពលភាពត្រឹមថ្ងៃទី…………..ខែ…………….ឆ្នាំ……………..។
សាមីខ្លួនត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន។

ថ្ងៃ………………………ខែ…………….ឆ្នាំ…………………….ព.ស. ……….
……………………….ថ្ងៃទី………….ខែ……………. ឆ្នាំ…………..
**អភិបាល**……………………..

ករណីមានភាពមិនប្រក្រតីនៃការបម្រើសេវា សូមមេត្តាទំនាក់ទំនងលេខទូរសព្ទ
- ប្រធានការិយាល័យច្រកចេញចូលតែមួយ ……………………….
- ប្រធានការិយាល័យប្រជាពលរដ្ឋ ………………………….

(ឧបសម្ព័ន្ធទី២)

# ពាក្យស្នើសុំ
# ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈអន្តរជាតិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# ពាក្យស្នើសុំ
# ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈអន្តរជាតិ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ................................ អក្សរឡាតាំង ..............................................
ភេទ............ថ្ងៃខែឆ្នាំកំណើត.........................សញ្ជាតិ................. អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ...........
ផ្លូវ...............ភូមិ....................... ឃុំ/សង្កាត់...............................ក្រុង/ស្រុក/ខណ្ឌ.........................
រាជធានី/ខេត្ត.................................. អត្តសញ្ញាណបណ្ណ / លិខិតឆ្លងដែនលេខ ...............................
លេខទូរសព្ទទំនាក់ទំនង .........................................................................................................

ជាម្ចាស់/តំណាង..............................................................................................................។

**សូមគោរពជូន**
**ឯកឧត្តម/លោកជំទាវអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត**
...................................................

**កម្មវត្ថុ** ៖ សំណើសុំប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈអន្តរជាតិ។

សេចក្ដីដូចបានជម្រាបជូនក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ-នាងខ្ញុំសូមគោរពជូន **ឯកឧត្តម/លោកជំទាវអភិបាលរាជធានី ខេត្ត** មេត្តាជ្រាបថា÷ ក្រុមតន្ត្រី ................................................ ..................របស់ខ្ញុំបាទ-នាងខ្ញុំមានបំណងប្រគំតន្ត្រីតាមទីសាធារណៈលក្ខណៈអន្តរជាតិចាប់ពីថ្ងៃទី........... ខែ ..................ដល់ថ្ងៃទី.................ខែ....................ឆ្នាំ............. នៅ..................................................... ...............................................................................................................................។

អាស្រ័យដូចបានគោរពជូនខាងលើ សូម **ឯកឧត្តម/លោកជំទាវ** មេត្តាពិនិត្យនិងសម្រេច។

*សូមជូនភ្ជាប់មកជាមួយ៖*

១- អត្តសញ្ញាណបណ្ណ ឬ លិខិតឆ្លងដែនរបស់អ្នកដាក់ពាក្យស្នើសុំ (ថតចម្លងដោយនីត្យានុកូលកម្ម) ១ច្បាប់
២- កិច្ចសន្យា ១ច្បាប់
៣- បញ្ជីរាយនាមតន្ត្រីករ សិល្បករ និងសិល្បការិនី ១ច្បាប់
៤- លិខិតឆ្លងដែនតន្ត្រីករ សិល្បករ និងសិល្បការិនីបរទេស (ថតចម្លងដោយនីត្យានុកូលកម្ម) ១ច្បាប់

សូម **ឯកឧត្តម/លោកជំទាវអភិបាល** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ-នាងខ្ញុំ។

ថ្ងៃ.......................... ខែ.............. ឆ្នាំ.........................ព.ស. ...........
ថ្ងៃទី...........ខែ.................... ឆ្នាំ..............

**ស្នាមមេដៃស្ដាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចសន្យា
## ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈអន្តរជាតិ

ខ្ញុំបាទ-នាងខ្ញុំឈ្មោះ.................................... ជាអក្សរឡាតាំង ............................................. ភេទ............ថ្ងៃខែឆ្នាំកំណើត......................... សញ្ជាតិ................ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ........... ផ្លូវ...............ភូមិ...................... ឃុំ/សង្កាត់...........................ក្រុង/ស្រុក/ខណ្ឌ ........................រាជធានី/ខេត្ត .........................តួនាទី(ម្ចាស់ ឬ អ្នកគ្រប់គ្រង)............................................ប្រកបអាជីវកម្មឈ្មោះ(ខ្មែរនិងឡាតាំង).................................................................ទូរសព្ទ.......................................... ទូរសារ......................... ..................... អ៊ីម៉ែល ឬ វេបសាយ..............................................។

### សូមធ្វើកិច្ចសន្យាដូចខាងក្រោម៖

១- ជានាគោរពគោលការណ៍និងទម្រង់សិល្បៈរបស់ជាតិ មិនកែច្នៃខុសពីលំនាំដើម

២- ជានារាល់ការប្រគំតន្ត្រី ឬ សម្ដែង ត្រូវគោរពតាមគោលការណ៍ណែនាំរបស់រដ្ឋបាលរាជធានី ខេត្ត និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

៣- ជានាមិនធ្វើឲ្យប៉ះពាល់ដល់ទំនៀមទម្លាប់ប្រពៃណីល្អរបស់ជាតិ

៤- ជានារាល់ការប្រគំតន្ត្រី ឬ សម្ដែងមិនឲ្យមានការប៉ះពាល់អង្គព្រះមហាក្សត្រ ការរើសអើងជាតិសាសន៍ ភេទ ព័ណ៌សម្បុរ ជំនឿ សាសនា ឬ និន្នាការនយោបាយដែលប្រឆាំងទៅនឹងបូរណភាពទឹកដី ឯករាជ្យជាតិ អធិបតេយ្យជាតិ ឬ សន្តិសុខជាតិ

៥- ជានាមិនឲ្យហួសម៉ោងកំណត់

៦- ជានាសហការល្អជាមួយអាជ្ញាធរមានសមត្ថកិច្ចគ្រប់លំដាប់ថ្នាក់

៧- ទទួលខុសត្រូវលើសន្តិសុខ សណ្ដាប់ធ្នាប់សាធារណៈ និងបរិស្ថានល្អ

៨- សាមីខ្លួនត្រូវទទួលខុសត្រូវចំពោះមុខច្បាប់រាល់ការសម្ដែងដែលរំលោភបំពានផ្នែកកម្មសិទ្ធិបញ្ញា។

អាជ្ញាធរមានសមត្ថកិច្ច មានសិទ្ធិផ្អាកជាបណ្ដោះអាសន្ន ឬ បញ្ឈប់ជាផ្លូវការរាល់ការប្រគំតន្ត្រី ឬ ការសម្ដែងណាដែលពិនិត្យឃើញថាមិនបានគោរពតាមកិច្ចសន្យាខាងលើ។

ករណីមិនអនុវត្តកិច្ចសន្យានេះ ខ្ញុំបាទ-នាងខ្ញុំសូមទទួលទោសតាមច្បាប់របស់រដ្ឋដែលបានកំណត់ជាធរមាន។

ថ្ងៃ.......................... ខែ.............. ឆ្នាំ..........................ព.ស. ...........

ថ្ងៃទី...........ខែ..................... ឆ្នាំ..............

**ស្នាមមេដៃស្ដាំ និង ឈ្មោះអ្នកស្នើសុំ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# បញ្ជីរាយនាម
## មន្ត្រីករ សិល្បករ និងសិល្បការិនីនៃការប្រគំមន្ត្រីតាមទីសាធារណៈជាលក្ខណៈអន្តរជាតិ

១. បញ្ជីរាយនាមតន្ត្រីករ សិល្បករ និងសិល្បការិនីជនជាតិខ្មែរ

| ល.រ. | គោត្តនាមនិងនាម | ភេទ | មុខងារ | អាសយដ្ឋានបច្ចុប្បន្ន | ផ្សេងៗ |
|---|---|---|---|---|---|
| ១ | | | | | |
| ២ | | | | | |
| ៣ | | | | | |
| ៤ | | | | | |
| ៥ | | | | | |
| ៦ | | | | | |
| ៧ | | | | | |
| ៨ | | | | | |
| ៩ | | | | | |

២. បញ្ជីរាយនាមតន្ត្រីករ សិល្បករ និងសិល្បការិនីសញ្ជាតិបរទេសដែលពុំមានលំនៅអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា

| ល.រ. | គោត្តនាមនិងនាម | ភេទ | មុខងារ | អាសយដ្ឋានបច្ចុប្បន្ន | លេខលិខិតឆ្លងដែន | សញ្ជាតិ |
|---|---|---|---|---|---|---|
| ១ | | | | | | |
| ២ | | | | | | |
| ៣ | | | | | | |
| ៤ | | | | | | |
| ៥ | | | | | | |
| ៦ | | | | | | |
| ៧ | | | | | | |
| ៨ | | | | | | |
| ៩ | | | | | | |

ចំនួនសរុប......................នាក់ ស្រី.........នាក់។

ថ្ងៃ............................ ខែ.............. ឆ្នាំ............................ព.ស. ............
ថ្ងៃទី..............ខែ..................... ឆ្នាំ..............
ស្នាមមេដៃស្តាំ និង ឈ្មោះអ្នកស្នើសុំ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រដ្ឋបាល** ……………………………

**អង្គភាពច្រកចេញចូលតែមួយ**

**លេខ** ………………………

## លិខិតអនុញ្ញាត
## ការប្រគំតន្ត្រីតាមទីសាធារណៈជាលក្ខណៈអន្តរជាតិ

**យោង** ៖ – អនុក្រឹត្យលេខ១៨ អនក្រ.បក ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតយន្តការច្រកចេញចូលតែមួយសម្រាប់ការផ្តល់សេវារដ្ឋបាលនៅថ្នាក់ក្រោមជាតិ

– ប្រកាសរួមលេខ៦៥៧ សហវ.ប្រក រវាងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

– ប្រកាសលេខ១៥ ប្រ.ក. ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ២០១៩ ស្តីពីកាគ្រប់គ្រងការប្រគំតន្ត្រីតាមទីសាធារណៈរបស់ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ

អនុញ្ញាតឲ្យឈ្មោះ………………………………… ភេទ………… ថ្ងៃខែឆ្នាំកំណើត……………………………………សញ្ជាតិ………………អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ……………… ផ្លូវ…………
ភូមិ…………………… ឃុំ/សង្កាត់ …………………………… ស្រុក/ខណ្ឌ ……………………………
រាជធានី/ខេត្ត……………………អត្តសញ្ញាណបណ្ណ / លិខិតឆ្លងដែនលេខ ……………………………
ប្រគំតន្ត្រី នៅភូមិ …………… ឃុំ/សង្កាត់ …………………… ស្រុក/ខណ្ឌ ……………………………
រាជធានី/ខេត្ត………………………។
លិខិតអនុញ្ញាតនេះមានសុពលភាពត្រឹមថ្ងៃទី…………ខែ……………ឆ្នាំ……………។
សាមីខ្លួនត្រូវអនុវត្តឲ្យបានត្រឹមត្រូវតាមបទប្បញ្ញត្តិជាធរមាន។

ថ្ងៃ…………………… ខែ………… ឆ្នាំ……………………… ព.ស. ………
…………………… ថ្ងៃទី………… ខែ…………… ឆ្នាំ…………

**អភិបាល**……………………

ករណីមានភាពមិនប្រក្រតីនៃការបម្រើសេវា សូមមេត្តាទំនាក់ទំនងលេខទូរសព្ទ

- ប្រធានអង្គភាពច្រកចេញចូលតែមួយ ……………………
- ប្រធានការិយាល័យប្រជាពលរដ្ឋ ……………………